សេចក្តីជូនដំណឹងអំពីការផ្លាស់ប្តូរដែលគួរឱ្យកត់សម្គាល់ចំពោះសៀវភៅផ្តល់ព័ត៌មានដល់សមាជិក

ថ្ងៃទី 15 ខែមេសា ឆ្នាំ 2025

ចាប់ពីថ្ងៃទី 15 ខែឧសភា ឆ្នាំ 2025 តទៅ សៀវភៅផ្តល់ព័ត៌មានដល់សមាជិកអំពីប្រព័ន្ធចែកចាយថ្នាំពេទ្យដែលរៀបចំឡើងដោយកម្មវិធីជាន់ប់រង Medi-Cal នៃខោនធី Los Angeles (Los Angeles County Drug Medi-Cal Organized Delivery System Member Handbook) នឹងមានការធ្វើឱ្យថ្មីឡើងវិញតាមរយៈសេចក្តីបន្ថែមទៅនឹងសៀវភៅនេះ។

ការផ្លាស់ប្តូរទៅសៀវភៅផ្តល់ព័ត៌មាននេះគឺដោយសារការដាក់បន្ថែម *គំរូអនុវត្តន៍ថែទាំសុខភាពតាមបែបប្រពៃណី (Traditional Health Care Practices)* សម្រាប់សមាជិកទាំងឡាយដែលមានសិទ្ធិក្នុងទទួលបានសេវាកម្មនេះ ហើយរំពឹងទុកថានឹងធ្វើឱ្យការអាចទទួលបានការថែទាំដោយមានការយល់ដឹងអំពីវប្បធម៌ខុសៗគ្នានោះ បានប្រសើរឡើង។

ដើម្បីពិនិត្យមើលឯកសារដែលបានធ្វើឱ្យថ្មីឡើងវិញនេះ (អាចរកបានជាច្រើនភាសាខុសៗគ្នាផងដែរនោះ) សូមចូលទៅកាន់គេហទំព័រផ្តល់ធនធាន និងព័ត៌មានដល់អ្នកទទួលការព្យាបាលផ្នែកការទប់ស្កាត់ និងការគ្រប់គ្រងការប្រើប្រាស់សារធាតុញៀន (Substance Abuse Prevention and Control Patient Resource and Information) តាមរយៈ https://publichealth.lacounty.gov/sapc/PatientPublic។

ដើម្បីស្នើសុំច្បាប់ចម្លងជាលក្ខណៈបោះពុម្ពដោយមិនគិតថ្លៃ សូមសាកសួរទៅកាន់អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នក ហើយអ្នកនឹងទទួលបានមួយច្បាប់។

ប្រសិនបើអ្នកត្រូវការជំនួយជាភាសាផ្សេងមួយទៀត ជាអក្សរសម្រាប់មនុស្សមើលមិនឃើញ (braille) ឬជាអក្សរពុម្ពធំៗ ឬក៏ត្រូវការជំនួយឬសេវាកម្មបន្ទាប់បន្សំ (សម្រាប់ជនពិការ) នោះ ចំណុចទាំងនេះគឺអាចរកបានដោយមិនគិតថ្លៃនៅពេលស្នើសុំ តាមរយៈការទូរស័ព្ទទៅកាន់លេខ 1-888-742-7900 ហើយចុចលេខ 7។